អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការបង់ពន្ធជូនរដ្ឋគឺជាកាតព្វកិច្ច របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
ដើម្បីចូលរួមចំណែកការពារ និង ការអភិវឌ្ឍន៍មាតុភូមិកម្ពុជា

To Pay Tax Is The Obligation For All Cambodian People And
To Contribute To The Defense And Development Of Our Nation!




# សិក្ខាសាលា

# ស្តីពី

# “កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងកាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ”

**សហការរៀបចំដោយ**

**ក្រុមប្រឹក្សាជាតិគណនេយ្យ និងអគ្គនាយកដ្ឋានពន្ធដារ**

**រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨**

**សណ្ឋាគារសុខាភ្នំពេញ**




# កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

## រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨

**នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**




# មាតិកា

១. កម្មវត្ថុនៃពន្ធលើប្រាក់ចំណូល

២. អត្រាពន្ធ

៣. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

៤. ពន្ធអប្បបរមា

៥. វិធានគណនេយ្យ




# មាតិកា (ត)

៦. គោលការណ៍នៃផលអាជីវកម្ម

៧. ចំណាយអាជីវកម្ម

៨. របៀបគណនាពន្ធលើប្រាក់ចំណូល

៩. កាតព្វកិច្ចត្រូវយកចិត្តទុកដាក់មួយចំនួន




# ១. កម្មវត្ថុនៃពន្ធលើប្រាក់ចំណូល

1. ជាបំណុលរបស់បុគ្គលនិវាសនជនចំពោះ÷
   - ប្រាក់ចំណូលប្រភពកម្ពុជា
   - ប្រភពបរទេស
2. ជាបំណុលរបស់បុគ្គលអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា




# ២. អត្រាពន្ធ (មាត្រា ២០. ថ្មី ចសព)

1. ២០% ប្រាក់ចំណូលជាប់ពន្ធរបស់នីតិបុគ្គល
2. ៣០% ប្រាក់ចំណូលជាប់ពន្ធ ក្រោមកិច្ចសន្យាបែងចែកផលិតផល÷
   - ប្រេងកាត
   - ឧស្ម័នធម្មជាតិ
   - ធនធានធម្មជាតិរួមទាំង ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា
3. ០% ប្រាក់ចំណូលជាប់ពន្ធរបស់ គ.ល.គ ស្ថិតក្នុងរយៈពេលលើកលែងពន្ធ




# ២. អត្រាពន្ធ [មាត្រា ២០. ថ្មី (មួយ)]

ប្រាក់ចំណូលជាប់ពន្ធ សម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ៖

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ (ចាប់ពីឆ្នាំ២០១៧) | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១២ 000 000 ៛ | 0% |
| ពី | ១២ 000 00១ ៛ | ដល់ | ១៨ 000 000 ៛ | ៥% |
| ពី | ១៨ 000 00១ ៛ | ដល់ | ១0២ 000 000 ៛ | ១0% |
| ពី | ១0២ 000 00១ ៛ | ដល់ | ១៥0 000 000 ៛ | ១៥% |
| | | លើសពី | ១៥0 000 000 ៛ | ២0% |




# ២. អត្រាពន្ធ (មាត្រា ២១. ថ្មី)

**អនុវត្តច្បាប់ចាស់ (ត្រឹមឆ្នាំ២០១៦)**

- ៥% នៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តនូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា។

**អនុវត្តច្បាប់ថ្មី (ចាប់ពីឆ្នាំ២០១៧)**

- ៥% នៃបុព្វលាភធានារ៉ាប់រងដុល ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា
- ២០% ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីចំណុចខាងលើ។




# ៣. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល (មាត្រា ២៨ ចសព)

1. សហគ្រាសជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែតាមអត្រា ១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ លើកលែងតែ អតប
2. គលគ ស្ថិតក្នុងរយៈពេលលើកលែងពន្ធត្រូវបានលើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនេះ
3. ប្រាក់រំដោះលើប្រាក់ចំណូលនឹងត្រូវយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។

# ៤. ពន្ធអប្បបរមា [មាត្រា ២៤ ថ្មី(ពីរ)]

- ពន្ធអប្បបរមាត្រូវកំណត់ស្មើនឹង ១ ភាគរយ នៃផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។
- ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណា ដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ។




## ៥. វិធានគណនេយ្យ

➢ **អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ** ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា÷

- ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះ**បានកើតឡើង** ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី
- ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធ**បានកើតឡើង** លទ្ធផលនៃ**សកម្មភាពសេដ្ឋកិច្ច**ដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និង**ចំនួនទឹកប្រាក់**ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់




(ផ្នែកទី 2.5 ប្រកាសពន្ធលើប្រាក់ចំណូល)

# ការកែតម្រូវក្រៅគណនេយ្យ

- តាមវិធានគណនេយ្យ ប្រាក់ចំណូលពិតគឺជាសមតុល្យនៃគណនី “លទ្ធផលនៃការិយបរិច្ឆេទ” ប៉ុន្តែដោយហេតុមានបទប្បញ្ញត្តិសារពើពន្ធដោយឡែកនោះ *លទ្ធផលពិតគណនេយ្យត្រូវតែជាកម្មវត្ថុនៃការកែតម្រូវក្រៅគណនេយ្យ*ដែលមាន**ការបញ្ចូលមកវិញ** និង**ការកាត់ចេញ**ផ្សេងៗ ។
- **ដោយហេតុថាមានបទប្បញ្ញត្តិដោយឡែកខាងពន្ធដារ**ប្រាក់ចំណូលជាប់ពន្ធតាមពន្ធដារ **មិនស្មើគ្នា** នឹងប្រាក់ចំណូលជាប់ពន្ធតាមគណនេយ្យទេ។




# ៦- គោលការណ៍នៃផលរបរជីវកម្ម

**១- អនុវត្តតាមគោលការណ៍គណនេយ្យទូទៅ ÷**

ចំណូលត្រូវតែកត់បញ្ចូល នៅក្នុងការិយបរិច្ឆេទដែលខ្ទង់ចំណូលនោះ**បានកើតឡើង** ទោះបីប្រាក់ចំណូលនោះ បានទូទាត់ ឬមិនទាន់ទូទាត់ក្តី ។

**២- ត្រូវកត់ត្រាចំណូលនៅពេលផ្គត់ផ្គង់**

ក- ពេលត្រូវចេញវិក្កយបត្រឬបានចេញវិក្កយបត្រប្រសិនបើវិក្កយបត្រត្រូវបានចេញមុនពេលត្រូវចេញ

ខ- យកទៅប្រើប្រាស់ផ្ទាល់ខ្លួន ÷ ពេលយកទៅប្រើប្រាស់ដំបូងសេវាត្រូវបានបំពេញរួចរាល់ ។

គ- ជាអំណោយ ÷ ពេលទំនិញត្រូវបានប្រគល់ឲ្យ ជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬសេវាត្រូវបានបំពេញរួចរាល់។




# ៦- គោលការណ៍នៃផលអាជីវកម្ម (ត)

## ២- ត្រូវកត់ត្រាចំណូលនៅពេលផ្គត់ផ្គង់ (ត)

**ចំពោះ÷**

-ភតិសន្យាហិរញ្ញវត្ថុ

-ការទូទាត់ច្រើនលើកឬសេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត

-សេវាខាងហិរញ្ញវត្ថុ

***យកកាលបរិច្ឆេទមុនគេក្នុងចំណោម:*** *ដល់កំណត់តាមកិច្ចសន្យា (ច្បាប់) ឬបានទទួលប្រាក់*




# ៧- ចំណាយអាជីវកម្ម

១- ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កង គឺបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ ដែលអ្នកជាប់ពន្ធបានធ្វើឡើងដើម្បីប្រកបអាជីវកម្ម និងដែលគ្មានការបញ្ចូលសំរាប់ជាថ្នូរមកវិញក្នុងទ្រព្យសកម្មនូវទ្រព្យសកម្មណាមួយ ឬដែលគ្មានការលុបបំណុលណាមួយខាងទ្រព្យអកម្ម។

២- ចំណាយបានទូទាត់ឬត្រូវសង**នៅក្នុងឆ្នាំជាប់ពន្ធ**÷ចំណាយណាមួយអាចកាត់កងបានតែពីលទ្ធផលនៃការិយបរិច្ឆេទដែលក្នុងអំឡុងពេលនោះ។

៣- **ចំណាយដើម្បីប្រកបអាជីវកម្ម៖** ត្រូវបានអនុញ្ញាតឱ្យកាត់កងបានតែចំណាយណាដែលបានធ្វើដើម្បីបំរើ ឬជាប្រយោជន៍នៃអាជីវកម្ម លើកលែងតែចំណាយកំសាន្តសប្បាយ ការសំរាកលំហែ ទទួលភ្ញៀវ អំណោយ ពិន័យខុសច្បាប់ និងការកំហិតដទៃទៀត ដូចជាការប្រាក់ ចំណាយសប្បុរសធម៌...




# ចំណាយអាចកាត់កងបាន

ត្រូវបំពេញនូវលក្ខខណ្ឌទាំងបី ដូចតទៅ ÷

ក- ហេតុការណ៍ដែលបញ្ជាក់នូវបន្ទុកឬ ចំណាយរបស់អ្នកជាប់ពន្ធបានកើតឡើង

ខ- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះ បានកើតឡើង។

គ- បន្ទុករបស់អ្នកជាប់ពន្ធត្រូវបានកំណត់ច្បាស់លាស់ :

- ត្រូវបានធ្វើគណនេយ្យកម្មក្នុងអំឡុងនៃការិយបរិច្ឆេទ
- ត្រូវមានភស្តុតាងបញ្ជាក់ត្រឹមត្រូវពីចំនួនទឹកប្រាក់ច្បាស់លាស់ (វិក្កយបត្រ...)




# ៨. របៀបគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

| | ការគណនា | | ការពិពណ៌នា | ទម្រង់ |
|---|---|---|---|---|
| 1 | | លទ្ធផលគណនេយ្យ | តារាងតុល្យការ របាយការណ៍លទ្ធផល<br>ថ្លៃដើមផលិតផល/ថ្លៃដើមទំនិញដែលបានលក់ | A, B, C, D |
| 2 | +/- | និយ័តកម្មពន្ធ | **ចំណាយមិនអាចកាត់កង** ចំណូលជាប់ពន្ធតែមិនបានកត់ត្រាក្នុងគណនេយ្យ **ចំណាយកាត់កងបាន** ចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ ចំណាយសប្បុរសធម៌មិនអនុញ្ញាត និយ័តកម្មលើការប្រាក់ ការយោងការខាតបង់ | តារាង E, F, G, |
| 3 | = | មូលដ្ឋានពន្ធ | | E |
| 4 | x % | ទឹកប្រាក់ពន្ធ | អត្រាថេរ (0%, 20%, 30%) ឬ អត្រាកំណើន (0% - 20%) | E |
| 5 | - | ឥណទានពន្ធ | ឥណទានពន្ធបរទេស<br>ពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ | E |
| 6 | > < | ពន្ធអប្បបរមា | 1% នៃផលរបរប្រចាំឆ្នាំ | E |
| 7 | - | ឥណទានពន្ធ | ពន្ធកាត់ទុក ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | E |
| 8 | = | ពន្ធលើប្រាក់ចំណូលត្រូវបង់ | | Page1→15 |

ប្រាក់ចំណេញ/ខាតមុនបង់ពន្ធតាមបញ្ជីគណនេយ្យ(E1)........................................XXX

បូក÷ ចំណាយមិនអាចកាត់កង(E2-E16) ........................................XXX

បូក÷ ចំណូលជាប់ពន្ធតែមិនបានកត់ត្រា បញ្ជីគណនេយ្យ(E18-E23) ........................XXX

ដក÷ ចំណាយមិនកត់ត្រាបញ្ជីគណនេយ្យ តែកាត់កងបាន(E25-E29) ......................(XXX)

ដក÷ចំណូល កត់ត្រាបញ្ជីគណនេយ្យ តែមិនត្រូវជាប់ពន្ធ (E31-E33)........................(XXX)

ប្រាក់ចំណេញ/ខាតក្រោយនិយ័តកម្ម (E35)........................................XXX

បូក÷ ចំណាយសប្បុរសធម៌មិនអាចកាត់កង(E36)........................................XXX

ប្រាក់ចំណេញ/ខាតមុននិយ័តកម្ម ការប្រាក់ (E37)........................................XXX

បូក/ដក÷ និយ័តកម្មលើការប្រាក់ (E38) ........................................XXX

ចំណេញ/ខាតក្នុងការិយបរិច្ឆេទ(E39) ........................................XXX

ដក÷ ខាតយោងពីឆ្នាំមុនអនុញ្ញាត(E40)........................................(XXX)

ប្រាក់ចំណូល/ខាតជាប់ពន្ធសម្រាប់គណនាពន្ធ (E41)........................................XXX

# តារាងគណនាពន្ធលើប្រាក់ចំណូល

**ពន្ធលើប្រាក់ចំណូល** ( E42) : (E4 1) x អត្រាពន្ធ.........................................................XXX

ដក÷ ឥណទានពន្ធបរទេស ( E43 ) .........................................................(XXX)

ពន្ធលើប្រាក់ចំណូលក្រោយដកឥណទានពន្ធបរទេស( E44 ) ..........................................XXX

ដក÷ ឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ ( E45 )..............................(XXX)

បំណុលពន្ធលើប្រាក់ចំណូល( E46 )..........................................................XXX

ពន្ធអប្បបរមា ( E47 )..........................................................XXX

បំណុលពន្ធលើប្រាក់ចំណូល(E46) ឬ ពន្ធអប្បបរមា(E47) ..........................................XXX

ដក÷ ឥណទានពន្ធកាត់ទុកបានបង់ក្នុងឆ្នាំ (E51) ..........................................(XXX)

ដក÷ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល(E52) ..........................................(XXX)

ដក÷ ឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន(E52.1) ..............................(XXX)

ពន្ធលើប្រាក់ចំណូលត្រូវបង់/យោងទៅឆ្នាំបន្ទាប់ ( E53 )..........................................XXX




# ៩. កាតព្វកិច្ចត្រូវយកចិត្តទុកដាក់មួយចំនួន

ក. ការយោងការខាតបង់

ខ. កាតព្វកិច្ចចំពោះសហគ្រាសដែលមានសាខាច្រើន

គ. កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឲ្យធ្វើសវនកម្មគណនេយ្យ

ឃ. ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម

ង. ទោសទណ្ឌល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ




# ក. ការយោងការខាតបង់

- អាចយោងខាតបង់សារពើពន្ធរហូតដល់ ៥ ឆ្នាំ
- ត្រូវប្រើប្រាស់លទ្ធផលសវនកម្មពន្ធដារ ចេញដោយ នាយកដ្ឋានសវនកម្មសហគ្រាស
- ដើម្បីអាចកាត់ចេញបាន ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាស
- អ្នកជាប់ពន្ធដែលទទួលរងការកំណត់ពន្ធឯកតោភាគីពីពន្ធដារ មិនត្រូវបានអនុញ្ញាតឱ្យយោងការខាតពីមុនមកកាត់ចេញទេ
- មិនអនុញ្ញាតឲ្យកាត់កងបានក្នុងករណីប្តូរកម្មវត្ថុអាជីវកម្ម ឬប្តូរម្ចាស់សហគ្រាស។




# ខ. កាតព្វកិច្ចចំពោះសហគ្រាសដែលមានសាខាច្រើន

(យោងតាមផ្នែក១៣.៤ កថាខណ្ឌ “ឃ” ប្រកាសស្តីពីពន្ធលើប្រាក់ចំណូល):

- ដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំស្តីពីលទ្ធផលសរុបបញ្ចូលរួមគ្នា មករដ្ឋបាលសារពើពន្ធ
- ភ្ជាប់របាយការណ៍ចំណូលចំណាយ នៃសាខានីមួយៗ ជាមួយនឹង លិខិតប្រកាសពន្ធប្រចាំឆ្នាំស្តីពីលទ្ធផលសរុបបញ្ចូលរួមគ្នា




# គ. កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឲ្យធ្វើសវនកម្មគណនេយ្យ

សហគ្រាសគ្រប់ប្រភេទតម្រូវឲ្យដាក់របាយការណ៍ហិរញ្ញវត្ថុធ្វើសវនកម្មដោយសវនករជំនាញឯករាជ្យ÷

-ប្រកាសលេខ ៦៤៣ សហវ ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧÷ ផ្អែកតាមលក្ខខ័ណ្ឌ២ ក្នុងចំណោម ៣ : (១)ផលរបរ≥ ៣ពាន់លានរៀល (២)ទ្រព្យសកម្ម≥២ពាន់លានរៀល និង(៣)ចំនួនបុគ្គលិក≥ ១០០ នាក់ **និង គលត។**

-ប្រកាស លេខ ១១៣០ សហវ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៧÷ **សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ** ព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល រហូតដល់ដំណាច់ឆ្នាំ២០២២ ត្រូវផ្សារភ្ជាប់ជាមួយនឹងអនុលោមភាពសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចខាងក្រោម÷

១. កាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ និង បទប្បញ្ញត្តិនៃច្បាប់ស្តីពីគណនេយ្យជាធរមាន

២. ប្រកាសបង់ពន្ធអាករដទៃទៀតជាធរមានទៅតាមកាលកំណត់ និង

៣. ផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធ។




# ឃ. ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម

ក. មានឥណទានអាករលើធាតុចូលលើសប្រចាំខែ ចំពោះបុគ្គលជាប់អាករដែលមានការនាំចេញជាសំខាន់ ឬបានចុះបញ្ជីជាសហគ្រាសវិនិយោគ

ខ. មានឥណទានអាករលើធាតុចូលលើសចាប់ពី ៣ខែ ជាប់គ្នា ឡើងទៅ ចំពោះបុគ្គលជាប់អាករដទៃទៀត

គ. មានភ័ស្តុតាងនៃការបង់ប្រាក់អាករលើធាតុចូល រួមមានប្រតិវេទន៍គយសម្រាប់ការនាំចូល ព្រមទាំងច្បាប់ដើមនៃបង្កាន់ដៃគយ ដែលបញ្ជាក់ពីការបង់ប្រាក់អាករដែលអាចអនុញ្ញាតជាឥណទាន ឬច្បាប់ដើមនៃវិក្កយបត្រអាករចេញដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក

ឃ. មានភ័ស្តុតាងនៃការនាំចេញដែលត្រូវជាប់អាករតាមអត្រាសូន្យ

ង. មានបញ្ជីគណនេយ្យអាករលើតម្លៃបន្ថែមដែលអាចជឿទុកចិត្តបាន រួមមាន ទិនានុប្បវត្តិទិញ-លក់ ព្រមទាំង កំណត់ត្រាជំនួយផ្សេងៗ។




# ខ. ទោសទណ្ឌល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

| បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ | | ពិន័យ និងទោសទណ្ឌ |
|---|---|---|
| ▪ ការធ្វេសប្រហែស | - **ការធ្វេសប្រហែស** (មាត្រា ១២៥)៖<br>▪ ប្រាក់ពន្ធបង់ខ្វះ ≤ ១០% នៃប្រាក់ពន្ធត្រូវបង់តាមច្បាប់ពន្ធដារ<br>▪ មិនបានដាក់លិខិតប្រកាសសារពើពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់។ | ▪ ពន្ធបន្ថែម ១០% នៃប្រាក់ពន្ធបង់យឺតឬខ្វះ<br>▪ ការប្រាក់ ២% ក្នុងមួយខែ |
| | - **ការធ្វេសប្រហែសធ្ងន់ធ្ងរ** (មាត្រា ១២៦)៖<br>▪ ប្រាក់ពន្ធបង់ខ្វះ > ១០% នៃប្រាក់ពន្ធត្រូវបង់តាមច្បាប់ពន្ធដារ | ▪ ពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធបង់ខ្វះ<br>▪ ការប្រាក់ ២% ក្នុងមួយខែ |




# ខ. ទោសទណ្ឌលើសបទប្បញ្ញត្តិស្តីពីពន្ធដារ (ត)

**បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ** | **ពិន័យ និងទោសទណ្ឌ**

- **ការគេចវេសពន្ធ**

  - បទល្មើសដោយចេតនាដោយដឹងជាមុន មានការរៀបចំទុក និងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវ ឱ្យបង់។
  - ល្មើសមាត្រា១២៧ ធ្វេសប្រហែសធ្ងន់ធ្ងរ ២លើក ដាច់ពីគ្នាយៈពេល ៣ឆ្នាំ នៃឆ្នាំប្រតិទិន។
  - ល្មើសមាត្រា១២៧ ធ្វេសប្រហែសធ្ងន់ធ្ងរ ៣លើក ឬច្រើនជាងនេះ ដាច់ពីគ្នាក្នុងរយៈពេលណាមួយក៏ដោយ។

**ការកំណត់ពន្ធឯកតោភាគី**
- ពន្ធបន្ថែម ៤០% នៃប្រាក់ពន្ធបង់ខ្វះ
- ការប្រាក់ ២% ក្នុងមួយខែ

**- ទោសទណ្ឌព្រហ្មទណ្ឌ**
- អភិបាល បណ្ណាធិការ កម្មសិទ្ធិករ ឬ បុគ្គលទទួលខុសត្រូវ បានប្រព្រឹត្តអំពើគេចវេសពន្ធ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី **១០ លាន រៀល ដល់ ២០ លានរៀល ឬជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ឬ ទោសទាំងពីរនេះ។**




# ខ. ទោសទណ្ឌល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ (ត)

## កំហុសឆ្គងចាត់ទុកជាអំពើរាំងស្ទះ

**អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (មាត្រា ១២៨)**

- ✓ មិនបានរក្សាបញ្ជីការគណនេយ្យ និងឯកសារផ្សេងទៀតឬមិនចេញវិក្កយប័ត្រលើកិច្ចការជំនួញ
- ✓ មិនអនុញ្ញាតិឲ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីការគណនេយ្យ និងឯកសារផ្សេងទៀត
- ✓ មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- ✓ មិនបានជូនដំណឹងរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី
- ✓ កសាង ឬផ្តល់កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ
- ✓ លាក់ទុក ឬបំផ្លាញដោយចេតនានូវបញ្ជីការគណនេយ្យ កំណត់ត្រា ឯកសាររបាយការណ៍ ឬព័ត៌ផ្សេងទៀត
- ✓ ព្យាយាមធ្វើឲ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ
- ✓ មិនដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទ ច្បាប់កំណត់
- ✓ ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ

## -ទោសទណ្ឌ (ពន្ធបន្ថែម)

**២,០០០,០០០ រៀល**
ចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកជាប់ពន្ធរបបពិត
(ស្វ័យប្រកាស)

## - ទោសទណ្ឌព្រហ្មទណ្ឌ
(មាត្រា ១៣៦)


To Pay Salary For Civil Servants
To Build Hospitals
To Pay Salary For Soldiers And Forces
To Build Roads
TAXES
To Build Bridges
To Defend Borders & Heritages
To Build Schools

# សូមអរគុណ